ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារលិខិតជូនពរ

## សម្តេច ឧបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លា ដែលឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបាន **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ប្រោសព្រះរាជទានគោរមងារជា **សម្តេចឧបុលបញ្ញា សុខ អាន** នាថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៧។

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ សូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយ និងអបអរសាទរចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យ ដែលទទួលបាននូវគោរមងារ ដ៏វិសេសវិសាល ថ្លៃថ្លានេះ គឺជាការផ្តល់នូវមហាកិត្តិយសដ៏ឧត្តុង្គឧត្តមសម្រាប់ **សម្តេច** និងក្រុមគ្រួសារ ជាការឆ្លើយតបយ៉ាងស័ក្តិសមបំផុត ចំពោះស្នាដៃរបស់ **សម្តេច** ក្នុងនាមជាថ្នាក់ដឹកនាំដ៏ឆ្នើម នៅក្នុងស្ថាប័នទីស្តីការគណៈរដ្ឋមន្ត្រី រួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ រីកចំរើនលើគ្រប់វិស័យ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ កងយោធពលខេមរភូមិន្ទ សូមជូនពរ**សម្តេចឧបុលបញ្ញា សុខ អាន** សូមមានសុខភាពល្អ បរិបូរណ៍ អាយុយឺនយូរ ដើម្បីចូលរួមចំណែកដឹកនាំប្រទេសជាតិ ប្រកបដោយសុខសន្តិភាព វឌ្ឍនភាព និងវិបុលភាពតរៀងទៅ។

សូម **សម្តេចឧបុលបញ្ញា សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី ជាទីស្រឡាញ់ជួបតែសេចក្តីសុខ សុភមង្គលនិងប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh